
JOINT COMMISSIO
DEMARCATION FOR LAND BOUNDARY

បកប្រែក្រៅផ្លូវការ

**សេចក្តីប្រកាសព័ត៌មានរួម**
**កិច្ចប្រជុំពិសេសគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក (JBC) កម្ពុជា-ថៃ**
**ខេត្តចន្ទបុរី, ព្រះរាជាណាចក្រថៃ, ថ្ងៃទី២១-២២ ខែតុលា ឆ្នាំ២០២៥**

១. កិច្ចប្រជុំពិសេសគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក (JBC) កម្ពុជា-ថៃ បានធ្វើឡើងនៅខេត្តចន្ទបុរី នៅថ្ងៃទី២១-២២ ខែតុលា ឆ្នាំ២០២៥។ គណៈប្រតិភូកម្ពុជាដឹកនាំដោយ ឯកឧត្តម **ឡាំ ជា** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែននៃព្រះរាជាណាចក្រកម្ពុជា និងជាសហប្រធានគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក (JBC) កម្ពុជា-ថៃ (ភាគីកម្ពុជា)។ គណៈប្រតិភូថៃដឹកនាំដោយឯកឧត្តម Prasas Prasasvinitchai ទីប្រឹក្សាក្រសួងការបរទេសនៃព្រះរាជាណាចក្រថៃ និងជាសហប្រធានគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក (JBC) ថៃ-កម្ពុជា (ភាគីថៃ)។

២. កិច្ចប្រជុំបានធ្វើឡើងក្នុងបរិយាកាសមិត្តភាព និងស្និទ្ធស្នាល។

៣. ភាគីទាំងពីរបានឯកភាពប្រគល់ភារកិច្ចជូនអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែន (JTSC) កម្ពុជា-ថៃ ដើម្បីសាងសង់ឡើងវិញនូវបង្គោលព្រំដែនចំនួន ១៥ តាមគំរូដើមបង្គោលជំនាន់បារាំងនៅទីតាំងដែលភាគីទាំងពីរបានឯកភាពគ្នាលើទីតាំងដើម។

៤. ភាគីទាំងពីរបានឯកភាពសាងសង់ឡើងវិញនូវបង្គោលព្រំដែនលិចទឹកចំនួន ៣ នៅទីតាំងដែលភាគីទាំងពីរនឹងឯកភាពគ្នា។

៥. ភាគីទាំងពីរបានឯកភាពពន្លឿនការកែសម្រួលបែបបទបច្ចេកទេស (TOR) ឆ្នាំ២០០៣ ទាក់ទងនឹងការផលិតផែនទីអ័រតូហ្វូតូ (ចំណុចទី ៤ ជំហានទី ២ នៃ TOR ឆ្នាំ ២០០៣) ដោយប្រើប្រាស់បច្ចេកវិទ្យាថ្មីដូចជា LiDAR (Light Detection and Ranging) ដើម្បីពន្លឿនការងារវាស់វែង និងខណ្ឌសីមាព្រំដែន។

៦- ពាក់ព័ន្ធនឹងករណីការចុះវាស់វែង និងខណ្ឌសីមាព្រំដែននៅលើដីជាក់ស្តែងក្នុងកំណាត់ខ្សែព្រំដែនចន្លោះបង្គោលលេខ 42-47 នៅក្នុងតំបន់ភូមិជោគជ័យ-ណងចាន់ និងតំបន់ភូមិព្រៃចាន់-ណងយ៉ាកែវ៖

   ក. ភាគីទាំងពីរបានឯកភាពពិនិត្យកែសម្រួលបញ្ចប់បែបបទណែនាំបច្ចេកទេស (TI) សម្រាប់ការវាស់វែងរួមគ្នា និងបោះបង្គោលបណ្តោះអាសន្ន នៅកំណាត់ខ្សែព្រំដែនអាទិភាពនៅចន្លោះបង្គោលលេខ 42-47។

   ខ. បន្ទាប់ពីបញ្ចប់ការវាស់វែងនិងបោះបង្គោលបណ្តោះអាសន្ន ព្រមទាំងទទួលបានការយល់ព្រមពីរដ្ឋាភិបាលរៀងខ្លួន ភាគីទាំងពីរនឹងស្នើសុំយោបល់ពីរដ្ឋាភិបាលរៀងៗខ្លួន ដើម្បីពិនិត្យសម្រេចលើការបង្កើតយន្តការសមស្របណាមួយ សម្រាប់ធ្វើការកែសម្រួលការកាន់កាប់និងអាស្រ័យផលរបស់ភាគីទាំងពីរ។

   គ. ការបោះបង្គោលបណ្តោះអាសន្ន គឺធ្វើឡើងក្នុងគោលបំណងបម្រើឱ្យការវាស់វែងប៉ុណ្ណោះ ដោយមិនត្រូវប៉ះពាល់ដល់ខ្សែព្រំដែនអន្តរជាតិកម្ពុជា-ថៃ។

ឃ. ភាគីទាំងពីរបានឯកភាពសម្របសម្រួលណែនាំដល់អាជ្ញាធរមូលដ្ឋាន រួមទាំងកងកម្លាំងយោធា និងជនស៊ីវិល ដើម្បីចូលរួមធានាសុវត្ថិភាព និងមិនរារាំងដល់ក្រុមវាស់វែងចម្រុះ ព្រមទាំងត្រូវចៀសវាងរាល់សកម្មភាពបង្កហេតុ ដែលអាចបង្កើតភាពតានតឹងបន្ថែមទៀតនៅក្នុងតំបន់នេះ ហើយត្រូវធានាសុវត្ថិភាពពីគ្រាប់មីន ដោយអនុលោមតាមមាត្រា ៣ នៃ MOU ឆ្នាំ ២០០០។

៧. ភាគីទាំងពីរបានឯកភាពថា កិច្ចប្រជុំបន្ទាប់របស់គណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក (JBC) នឹងប្រព្រឹត្តទៅនៅសប្តាហ៍ទីមួយនៃខែមករា ឆ្នាំ ២០២៦ នៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា។

*** ***

**Joint Press Statement**

**Special Meeting of the Cambodian - Thai Joint Commission on Demarcation for Land Boundary (JBC), Chanthaburi, Thailand, 21 - 22 October 2025**

1. The Special Meeting of the Cambodian - Thai Joint Commission on Demarcation for Land Boundary (JBC) was held in Chanthaburi on 21-22 October 2025. The Cambodian delegation was led by H.E. Mr. Lam Chea, Minister in charge of the State Secretariat of Border Affairs of the Kingdom of Cambodia, Co-Chairman of the Cambodian - Thai Joint Commission on Demarcation for Land Boundary (Cambodian side). The Thai delegation was led by H.E. Mr. Prasas Prasasvinitchai, Advisor to the Ministry of Foreign Affairs of the Kingdom of Thailand, Co-Chairman of the Thai - Cambodian Joint Commission on Demarcation for Land Boundary (Thai side).
2. The Meeting was held in an atmosphere of friendship and cordiality.
3. Both sides assigned the JTSC to replace 15 Boundary Pillars which both sides agreed on the location to their original locations and specifications.
4. Both sides agreed to replace 3 Boundary Pillars submerged in water at a position to be agreed upon by both sides.
5. Both sides agreed to accelerate the revision of Terms of Reference (TOR) 2003 regarding the production of orthophoto maps (Point 4, Step 2 of TOR 2003) by utilising new technologies such as LiDAR (Light Detection and Ranging) to expedite the survey and demarcation work.
6. Regarding the issues related to joint survey and demarcation in the segment of Boundary Pillars No. 42 to 47 in the area of Chouk Chey-Nong Chan Village and Prey Chan- Nong Ya Kaeo Village;
    a. Both sides agreed to finalize the Technical Instruction (TI) for Joint Survey and Emplacement of Temporary Markers of priority terrain segments from Boundary Pillars No. 42 to 47;
    b. After the completion of the survey and emplacement of temporary markers and approval by the respective governments, both sides will consult their respective governments to decide on any appropriate mechanism for the adjustment of land occupation of both sides;
    c. The emplacement of temporary markers is for survey purposes only and shall be without prejudice to the international boundary between Cambodia and Thailand; and
    d. Both sides agreed to impress upon local authorities, both military and civilian to ensure the safety of the Joint Survey Team and not to obstruct its work, and to refrain from any act of provocation that create further tension within the areas and shall first be assured of its safety from landmines pursuant to the Article 3 of the MOU 2000.
7. Both sides agreed that the next Meeting of the JBC will be held in the first week of January 2026 in Siem Reap, Cambodia.

*****